**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

P.T.C.

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
លេខ......៣៩៤......បទ........................

នាយកដ្ឋាននិយ័តកម្មទូរគមនាគមន៍
មកដល់ លេខ......1594......ន.ន.ទ
ថ្ងៃទី...27...ខែ...12...ឆ្នាំ២០18
ម៉ោង 11:30AM អ្នកទទួល..............

## សេចក្តីណែនាំ
## ស្តីពី
## ការទប់ស្កាត់បទល្មើសដំឡើងប្រព័ន្ធទូរគមនាគមន៍គ្រប់ប្រភេទ ដើម្បីទាញយកសេវាមកប្រើប្រាស់ដោយមិនឆ្លងកាត់ច្រកហៅចេញ-ចូលអន្តរជាតិ

**យោង ៖** - ព្រះរាជក្រម នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ ច្បាប់ស្តីពីទូរគមនាគមន៍

- សារាចរលេខ ០២ ស.រ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការទប់ស្កាត់សកម្មភាពលួចដំឡើងប្រព័ន្ធទូរស័ព្ទចេញ ចូលអន្តរជាតិ

កន្លងមកមានជនទុច្ចរិតមួយចំនួនបានឃុបឃិតគ្នាលួចរៀបចំដំឡើងប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធវិទ្យុគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដោយប្រើឧបករណ៍ (វិទ្យុម៉ាយក្រូវេវ អង់តែន YAGI TOPLINK SFR-TX CDMA/3G... គ្រឿងសម្ភារព័ត៌មានវិទ្យា និងខ្សែចម្លងស៊ីញ៉ាល់ទូរគមនាគមន៍គ្រប់ប្រភេទ) សម្រាប់ទទួលបញ្ជូន និងពង្រីកសេវាទូរគមនាគមន៍ **ដើម្បីទាញយកសេវាទូរគមនាគមន៍អន្តរជាតិមិនស្របច្បាប់** ពីប្រទេសជិតខាងមកប្រើប្រាស់នៅតាមបណ្តោយព្រំដែន (សណ្ឋាគារ កាស៊ីណូ ផ្ទះសំណាក់ លំនៅដ្ឋាន និងនៅតាមទីតាំងអាជីវកម្មមួយចំនួន) បង្កឱ្យមានការរំខាន ឬជ្រៀតជ្រែកលើហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូរគមនាគមន៍ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងក្រុមហ៊ុននានាដែលកំពុងបម្រើ សេវាទូរគមនាគមន៍ស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសធ្វើឱ្យបាត់បង់ចំណូលថវិកាជាតិ។ ដើម្បីលុបបំបាត់អំពើខុសច្បាប់ទាំងនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សូមធ្វើសេចក្តីណែនាំដូចខាងក្រោម៖

១. ត្រូវបញ្ឈប់ជាបន្ទាន់នូវការបង្កើត ការដំឡើង ការប្រើប្រាស់ ការកែប្រែហេដ្ឋារចនាសម្ព័ន្ធបណ្តាញទូរគមនាគមន៍ និងគ្រឿងបរិក្ខារ ដែលបង្កឱ្យមានការរំខាន ឬជ្រៀតជ្រែកលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ វិទ្យុគមនាគមន៍ និងព័ត៌មានវិទ្យាស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ត្រូវធ្វើការរុះរើទម្លាក់ និងបញ្ឈប់ការប្រើប្រាស់ នូវប្រព័ន្ធទូរស័ព្ទ ឧបករណ៍អង់តែន ទូរគមនាគមន៍ វិទ្យុគមនាគមន៍ (YAGI, TOPLINK, SFR-TX, CDMA/3G...) សម្ភារព័ត៌មានវិទ្យា និងខ្សែចម្លងស៊ីញ៉ាល់ទូរគមនាគមន៍គ្រប់ប្រភេទ ដែលបានដំឡើងរួច ដើម្បីទទួលបញ្ជូន និងពង្រីកសេវាទូរគមនាគមន៍មិនស្របច្បាប់យកមកប្រើប្រាស់។

៣. ជនពាក់ព័ន្ធដែលមិនព្រមអនុវត្តតាមសេចក្តីណែនាំខាងលើ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាប់ជនល្មើស និងវត្ថុតាងបញ្ជូនទៅតុលាការចាត់ការតាមនីតិវិធីច្បាប់។

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ.
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

ទទួលបានសេចក្តីណែនាំនេះ សូម អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ចូលរួមសហការ អនុវត្ត ឱ្យមានប្រសិទ្ធិភាពខ្ពស់។

ថ្ងៃ អង្គារ ១០ កើត ខែ មិគសិរ ឆ្នាំច សំរឹទ្ធស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

<u>ចម្លងជូន:</u>

-ក្រសួងមហាផ្ទៃ «ដើម្បីជូនជ្រាប»
-សាលារាជធានី-ខេត្ត-ក្រុង «ដើម្បីសហការអនុវត្ត»
-និយ័តករទូរគមនាគមន៍ «ដើម្បីសហការអនុវត្ត»
-គ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត
«ដើម្បីសហការអនុវត្ត»
-ឯកសារកាលប្បវត្តិ